ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០៤១១ អបភ-ឱអបភ

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មក ឆ្នាំ២០១១

# ប្រកាស

## ស្តីពី

## តួនាទី ភារកិច្ចរបស់ភ្នាក់ងារត្រួតពិនិត្យឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាង និងសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន

* * * * *

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ កញ្ញា ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រម ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០៩ ចុះថ្ងៃទី ២១ មិថុនា ឆ្នាំ២០០០ ប្រកាសអោយប្រើ ច្បាប់ ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា
- បានឃើញព្រះរាជក្រម នស/រកម/១១០០/១០ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០០ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈ ឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រម នស/រកម/១២០៧/០៣៧ ចុះថ្ងៃទី ២៨ ធ្នូ ២០០៧ ប្រកាសឱ្យប្រើច្បាប់ ស្តីពី វិសោធនកម្ម ច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ តុលា ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្របក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីពីបែបបទ និងល័ក្ខខ័ណ្ឌនៃការអនុញ្ញាតឱ្យជនបរទេស ជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៣៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ
- បានឃើញអនុក្រឹត្យលេខ ១២២អនក្រ.បក ចុះថ្ងៃទី ២៨ សីហា ២០០៨ ស្តីពីការគ្រប់គ្រងគ្រឿងសម្អាង
- បានឃើញប្រកាសអន្តរក្រសួងលេខ ០៦១សរនប ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០០៧ ស្តីពីការអនុវត្តន៍អនុក្រឹត្យស្តីពី ការផ្សព្វផ្សាយលក់ផលិតផល សម្រាប់ចិញ្ចឹមទារក និងកុមារ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៨៦៨ ឧរថ.ប្រក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ២០១០ ស្តីពីការអនុវត្តន៍ និងការរៀបចំសម្របសម្រួលស្ថាប័នកិច្ច នៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ ចាប់ពីកសិដ្ឋានផលិត ដល់តុបរិភោគ
- បានឃើញ ប្រកាសលេខ ០០៥៣ អ.ប.ស/ឱ.អ.ប.ស ចុះថ្ងៃទី ០៦-០២-២០០៩ របស់ក្រសួងសុខាភិបាល ស្តីពីល័ក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយឱសថ និងផលិតផលដែលមានគុណភាពក្នុងការបង្ការ ឬព្យាបាលជម្ងឺ
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល ។



ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល ,លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៤២៦ ០៣៥ ⁄ ៤២៦ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៩៣៣

## សម្រេច

**ប្រការ ១.-**

ភ្នាក់ងារត្រួតពិនិត្យឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាង និងសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន ជាភ្នាក់ងារត្រួតពិនិត្យសុខាភិបាល ត្រូវមានភារកិច្ចចុះណែនាំ ត្រួតពិនិត្យគ្រប់សកម្មភាពដែលពាក់ព័ន្ធនឹងផលិតកម្ម អាហរ័ណ នីហរ័ណកម្ម និងពាណិជ្ជកម្មឱសថសម័យ ឱសថបូរាណ ឱសថបំប៉នសុខភាព ឬផលិតផលបំប៉នសុខភាព បរិក្ខារពេទ្យ ប្រតិករ គ្រឿងសម្អាង អនាម័យ និងសុវត្ថិភាពចំណីអាហារ ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន សំដៅធានាការពារសុខភាពសាធារណៈ និងអាយុជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២.-**

**តួនាទី និងភារកិច្ចរបស់ភ្នាក់ងារត្រួតពិនិត្យឱសថ បរិក្ខារពេទ្យ និងគ្រឿងសម្អាង :**

**ក.វិសាលភាព :**

ភ្នាក់ងារត្រួតពិនិត្យឱសថ បរិក្ខារពេទ្យ និងគ្រឿងសម្អាង ត្រូវបែងចែកជា :

១-ភ្នាក់ងារត្រួតពិនិត្យឱសថ បរិក្ខារពេទ្យ និងគ្រឿងសម្អាង ថ្នាក់កណ្តាលមានវិសាលភាពត្រួតពិនិត្យទូទាំងព្រះរាជាណាចក្រកម្ពុជា

២-ភ្នាក់ងារត្រួតពិនិត្យឱសថ បរិក្ខារពេទ្យ និងគ្រឿងសម្អាង ថ្នាក់រាជធានី ខេត្ត មានវិសាលភាព ត្រួតពិនិត្យតែក្នុងដែនសមត្ថកិច្ចប៉ុណ្ណោះ ។

**ខ.តួនាទី និងភារកិច្ច :**

ភ្នាក់ងារត្រួតពិនិត្យឱសថ បរិក្ខារពេទ្យ និងគ្រឿងសម្អាង មានភារកិច្ចណែនាំ ត្រួតពិនិត្យ និងតាមដានការអនុវត្តច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ និង លិខិតបទដ្ឋានទាំងឡាយដែលពាក់ពន្ធ័នឹងផលិតកម្ម អាហរ័ណ នីហរ័ណកម្ម និងពាណិជ្ជកម្មឱសថសម័យ ឱសថបូរាណ ឱសថបំប៉នសុខភាព ឬផលិតផលបំប៉នសុខភាព បរិក្ខារពេទ្យ ប្រតិករ និងគ្រឿងសម្អាង នៅតាម :

-គ្រឹះស្ថានផលិតឱសថសម័យ គ្រឹះស្ថានវេចខ្ចប់ឱសថសម័យ គ្រឹះស្ថានផលិតឱសថបូរាណ និងគ្រឹះស្ថានផលិតសម្ភារៈបរិក្ខារពេទ្យ

-គ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថសម័យ ឱសថបូរាណ សម្ភារៈបរិក្ខារពេទ្យ និង គ្រឿងសម្អាង រួមទាំង សាខានៅតាមរាជធានី ខេត្ត

- ឱសថស្ថាន ឱសថស្ថានរង

- អគារលក់ឱសថបូរាណ និងគ្រឹះស្ថានលក់គ្រឿងសម្អាង

- ការិយាល័យតំណាងរោងចក្រផលិតឱសថក្រៅប្រទេស

- មជ្ឈមណ្ឌលថែរក្សាសម្ផស្សនៅតាមរាជធានី ខេត្ត ។

**គ.នីតិវិធីក្នុងការចុះត្រួតពិនិត្យ :**

រាល់ការចុះប្រតិបត្តិការភ្នាក់ងារត្រួតពិនិត្យឱសថ បរិក្ខារពេទ្យ និងគ្រឿងសម្អាង ត្រូវ :

-មានលិខិតបញ្ជាបេសកកម្ម ដែលចេញដោយប្រធានស្ថាប័នសាមី

-មានឯកសណ្ឋានជាភ្នាក់ងារត្រួតពិនិត្យ ។

<u>ប្រការ ៣.</u>-

**ការបែងចែកភារកិច្ចរវាងភ្នាក់ងារត្រួតពិនិត្យឱសថ បរិក្ខារពេទ្យ និង គ្រឿងសម្អាង ថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត**

**ក-ភ្នាក់ងារត្រួតពិនិត្យឱសថ បរិក្ខារពេទ្យ និងគ្រឿងសម្អាង ថ្នាក់កណ្តាលមានភារកិច្ច :**

១-ចុះត្រួតពិនិត្យតាមដានការអនុវត្តន៍ច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ លិខិតបទដ្ឋានរបស់ក្រសួងសុខាភិបាល នៅតាមបណ្តាគ្រឹះស្ថានផលិតឱសថសម័យ ឱសថបូរាណ ឱសថប៉ះពាល់សរសៃប្រសាទ និងឱសថដែលមានសារធាតុញៀន សម្ភារៈបរិក្ខារពេទ្យ និងគ្រឿងសម្អាង ក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានរៀងរាល់១ឆ្នាំម្តង ដោយប្រើឯកសារលក្ខណៈវិនិច្ឆ័យ (Check List) ក្នុងការវាយតម្លៃ ។ ក្នុងករណីចាំបាច់ការចុះត្រួតពិនិត្យបន្ទាន់ អាចប្រព្រឹត្តធ្វើបាន លុះត្រាតែមានការឯកភាព ពីថ្នាក់ដឹកនាំក្រសួងសុខាភិបាល ។

២-ចុះត្រួតពិនិត្យតាមដានការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងឱសថ លិខិតបទដ្ឋាននានា របស់ក្រសួងសុខាភិបាល នៅតាមបណ្តាគ្រឹះស្ថានអាហារ៍ណ នីហារ៍ណឱសថ គ្រឹះស្ថានអាហារ៍ណ នីហារ៍ណគ្រឿងសម្អាង សាខាគ្រឹះស្ថានអាហារ៍ណ នីហារ៍ណឱសថ សាខាគ្រឹះស្ថានអាហារ៍ណ នីហារ៍ណគ្រឿងសម្អាង ឱសថស្ថាន ឱសថស្ថានរង អគារលក់ឱសថបូរាណ គ្រឹះស្ថានលក់គ្រឿងសម្អាង និងមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ដោយប្រើឯកសារលក្ខណៈវិនិច្ឆ័យ (Check List) ក្នុងការវាយតម្លៃ។ ក្នុងករណី ចាំបាច់ការចុះត្រួតពិនិត្យបន្ទាន់អាចប្រព្រឹត្តធ្វើបាន លុះត្រាតែមានការឯកភាពពីថ្នាក់ដឹកនាំក្រសួងសុខាភិបាល ។

៣-ចុះតាមដានស្រាវជ្រាវការចរាចរណ៍ឱសថ និងផលិតផលផ្សេងៗនៅលើទីផ្សារ ករណីសង្ស័យត្រូវផ្អាកបណ្តោះអាសន្នការលក់ ឬចែកចាយឱសថ ឬផលិតផលទាំងនោះ រួចធ្វើសម្រង់ឱសថ ឬផលិតផលគំរូទាំងនោះ ដើម្បីធ្វើការត្រួតពិនិត្យគុណភាព និងរាយការណ៍ជូនថ្នាក់ដឹកនាំ ដើម្បីសម្រេច ។

៤-ចុះត្រួតពិនិត្យតាមដានការអនុវត្តន៍វិសហមជ្ឈការ និងវិមជ្ឈការ របស់ក្រសួងនៅតាមបណ្តាមន្ទីរសុខាភិបាលរាជធានី ខេត្ត រៀងរាល់ត្រីមាស ដោយប្រើឯកសារលក្ខណៈវិនិច្ឆ័យ (Check List) ក្នុងការវាយតម្លៃ ។

៥-ចូលរួមស្រាវជ្រាវ និងលុបបំបាត់ឱសថក្លែងក្លាយ ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

៦-តាមដានត្រួតពិនិត្យការផ្សព្វផ្សាយពាណិជ្ជកម្ម ឱសថសម័យ ឱសថបុរាណ ឱសថបំប៉នសុខភាព ឬផលិតផលបំប៉នសុខភាព ស្រាថ្នាំបុរាណគ្រប់ប្រភេទ សម្ភារៈបរិក្ខារពេទ្យ-ទន្តពេទ្យ សម្ភារៈប្រតិករសម្រាប់មន្ទីរពិសោធន៍វេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ គ្រឿងសម្អាង ផលិតផលដែលមានគុណភាពក្នុងការបង្ការ ឬព្យាបាលជម្ងឺ និងមជ្ឈមណ្ឌលថែរក្សាសម្ផស្ស តាមរយៈវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្ដី ព្រឹត្តប័ត្រវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ឬតាមរូបភាពផ្សេងៗទៀត ដែលមានខ្លឹមសារមិនត្រឹមត្រូវតាមលិខិតអនុញ្ញាត ឬគ្មានលិខិតអនុញ្ញាតរបស់ក្រសួងសុខាភិបាល ។

៧-ចុះត្រួតពិនិត្យវាយតម្លៃការសុំបើក ការសុំបិទ ការប្ដូរទីតាំង ការប្ដូរឱសថការីទទួលខុសត្រូវ និងបន្តសុពលភាពរបស់គ្រឹះស្ថានផលិតឱសថ គ្រឹះស្ថានអាហារ៍ណ នីហារ៍ណឱសថ គ្រឹះស្ថានអាហារ៍ណ នីហារ៍ណគ្រឿងសម្អាង សាខាគ្រឹះស្ថានអាហារ៍ណ នីហារ៍ណឱសថ សាខាគ្រឹះស្ថានអាហារ៍ណ នីហារ៍ណគ្រឿងសម្អាង ការិយាល័យតំណាងរោងចក្រផលិតឱសថក្រៅប្រទេស គ្រឹះស្ថានលក់គ្រឿងសម្អាង និងមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ដោយប្រើឯកសារលក្ខណៈវិនិច្ឆ័យ (Check List) ក្នុងការវាយតម្លៃ ។

៨-ពេលចុះអនុវត្តការងារក្នុងកន្លែងប្រកបអាជីវកម្ម ដូចបានកំណត់ក្នុងប្រការ២ ភ្នាក់ងារត្រួតពិនិត្យឱសថ បរិក្ខារពេទ្យ និងគ្រឿងសម្អាងមានសិទ្ធិឃាត់ទុកជាបណ្ដោះអាសន្ននូវ : ឱសថក្លែងក្លាយ ឱសថដែលក្រសួងហាមឃាត់ ឱសថគ្មានបិទលតប័ត្រ បរិក្ខារពេទ្យ ប្រតិករ និងគ្រឿងសម្អាង វត្ថុធាតុដើម វត្ថុធាតុផ្សំដែលផុតកំណត់កាលបរិច្ឆេទប្រើប្រាស់ និងវត្ថុតាងសង្ស័យផ្សេងៗ ហើយត្រូវធ្វើរបាយការណ៍ជូនប្រធានគណៈកម្មការអន្តរក្រសួងលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ សម្រាប់កាត់បន្ថយភាពក្រីក្រ ដើម្បីស្នើសុំមតិសម្រេច តាមរយៈលេខាធិការដ្ឋាន ។

៩-ចុះត្រួតពិនិត្យតាមដានរាល់ពាក្យបណ្ដឹងអំពីឱសថក្លែងក្លាយ ឱសថដែលក្រសួងហាមឃាត់ ឱសថគ្មានបិទលតប័ត្រ បរិក្ខារពេទ្យ ប្រតិករ គ្រឿងសម្អាង វត្ថុធាតុដើម វត្ថុធាតុផ្សំដែលផុតកំណត់កាលបរិច្ឆេទប្រើប្រាស់ និងវត្ថុតាងសង្ស័យផ្សេងៗ ហើយត្រូវធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងដើម្បីស្នើសុំមតិសម្រេច ។

**ខ- ភ្នាក់ងារត្រួតពិនិត្យឱសថ បរិក្ខារពេទ្យ និងគ្រឿងសម្អាង ថ្នាក់រាជធានី ខេត្ត :**

១-ចុះត្រួតពិនិត្យតាមដានការអនុវត្តន៍ច្បាប់ឱសថ លិខិតបទដ្ឋាននានារបស់ក្រសួងសុខាភិបាល នៅតាមបណ្ដាឱសថស្ថាន ឱសថស្ថានរង អាគារលក់ឱសថបុរាណ និងមជ្ឈមណ្ឌលថែរក្សាសម្ផស្សទាំងអស់ ក្នុងរាជធានី ខេត្ត ឱ្យបាន១កន្លែង ១ដងក្នុង១ត្រីមាស ដោយប្រើឯកសារលក្ខណៈវិនិច្ឆ័យ (Check List) ក្នុងការវាយតម្លៃ ។

២-ពេលចុះអនុវត្តការងារនៅតាមបណ្ដារថយន្តដឹកឱសថ ឱសថស្ថាន ឱសថស្ថានរង អគារលក់ឱសថបុរាណ កន្លែងលក់គ្រឿងសម្អាង និងមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ភ្នាក់ងារត្រួតពិនិត្យឱសថ បរិក្ខារពេទ្យ

២-ភ្នាក់ងារត្រួតពិនិត្យអនាម័យ និងសុវត្ថិភាពចំណីអាហារថ្នាក់រាជធានី ខេត្តមានវិសាលភាពត្រួតពិនិត្យ រាល់សកម្មភាពដែលទាក់ទងនឹងអនាម័យ និងសុវត្ថិភាពចំណីអាហារ តែក្នុងដែនសមត្ថកិច្ចប៉ុណ្ណោះ ។

**ខ_តួនាទី និងភារកិច្ច :**

ភ្នាក់ងារត្រួតពិនិត្យអនាម័យ និងសុវត្ថិភាពចំណីអាហារមានភារកិច្ចណែនាំ ត្រួតពិនិត្យ និងតាមដានការអនុវត្តន៍លិខិតបទដ្ឋានគតិយុត្តិដែលពាក់ពន្ធ័នឹងវិស័យអនាម័យ សុវត្ថិភាពចំណីអាហារ ខ្ទឹមសារ ស្លាកសញ្ញា និងបទរំលោភផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ឬផលិតផលប្រហាក់ប្រហែលនៅតាម :

-ភោជនីយដ្ឋាន អាហារដ្ឋាន ទីផ្សារ ទីសាធារណៈ គ្រឹះស្ថានលក់ និងចែកចាយផលិតផលចំណីអាហារ

-ឱសថស្ថាន ឱសថស្ថានរង ប្រព័ន្ធថែទាំសុខភាពដែលចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងការថែទាំសុខភាព ឬការអប់រំសុខភាពដល់ស្ត្រីជាមាតាទារក និង ស្ត្រីមានផ្ទៃពោះដោយរាប់បញ្ចូលទាំងទារកដ្ឋាន និងមជ្ឈមណ្ឌលថែទាំទារក និងកុមារ ។

**គ_នីតិវិធីក្នុងការចុះត្រួតពិនិត្យ :**

រាល់ការចុះប្រតិបត្តិការភ្នាក់ងារត្រួតពិនិត្យអនាម័យ និងសុវត្ថិភាពចំណីអាហារត្រូវ :

-មានលិខិតបញ្ជាបេសកកម្ម ដែលចេញដោយប្រធានស្ថាប័នសាមី

-មានឯកសណ្ឋានភ្នាក់ងារត្រួតពិនិត្យ ។

<u>ប្រការ ៥._</u>

**ការបែងចែកភារកិច្ចរវាងភ្នាក់ងារត្រួតពិនិត្យអនាម័យ និងសុវត្ថិភាពចំណីអាហារ ថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត :**

**ក-ភ្នាក់ងារត្រួតពិនិត្យអនាម័យ និងសុវត្ថិភាពចំណីអាហារថ្នាក់កណ្តាលមានភារកិច្ច :**

១-ចុះត្រួតពិនិត្យ តាមដានការអនុវត្តន៍ លិខិតបទដ្ឋានគតិយុត្តិ ដែលពាក់ព័ន្ធនឹងវិស័យអនាម័យសុវត្ថិភាពចំណីអាហារ ខ្ទឹមសារ ស្លាកសញ្ញា និងបទរំលោភផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ឬផលិតផលប្រហាក់ប្រហែល ក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានទៀងរាល់ត្រីមាស ដោយប្រើឯកសារលក្ខណៈវិនិច្ឆ័យ (Check List) ក្នុងការវាយតម្លៃ ។ ក្នុងករណីចាំបាច់ការចុះត្រួតពិនិត្យបន្ទាន់ អាចប្រព្រឹត្តធ្វើបានលុះត្រាតែមានការឯកភាពពីថ្នាក់ដឹកនាំក្រសួងសុខាភិបាល ។

និងគ្រឿងសម្អាង មានសិទ្ធិឃាត់ទុកជាបណ្ដោះអាសន្ននូវ : ឱសថក្លែងក្លាយ ឱសថដែលក្រសួងសុខាភិបាលហាមឃាត់ ឱសថគ្មានបិទលតប័ត្រ ឱសថផុតកំណត់កាលបរិច្ឆេទប្រើប្រាស់ ឱសថសង្ស័យ និងគ្រឿងសម្អាងដែលគ្មានលេខប្រវេទន៍ ហើយត្រូវធ្វើរបាយការណ៍ជូនប្រធានគណៈកម្មការរាជធានី ខេត្ត លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ ដើម្បីស្នើសុំមតិសម្រេច តាមរយៈលេខាធិការដ្ឋាន ។

៣-តាមដានត្រួតពិនិត្យការផ្សព្វផ្សាយពាណិជ្ជកម្ម ឱសថសម័យ ឱសថបូរាណ ឱសថបំប៉នសុខភាព ឬផលិតផលបំប៉នសុខភាព ស្រាថ្នាំបូរាណគ្រប់ប្រភេទ សម្ភារៈបរិក្ខារពេទ្យ-ទន្តពេទ្យ ប្រតិករសម្រាប់មន្ទីរពិសោធន៍វេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ គ្រឿងសម្អាង ផលិតផលដែលមានគុណភាពក្នុងការបង្ការ ឬព្យាបាលជម្ងឺ និងមជ្ឈមណ្ឌលថែរក្សាសម្ផស្ស តាមរយៈវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្ដី ព្រឹត្តប័ត្រវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ឬតាមរូបភាពផ្សេងៗទៀត ដែលមានខ្លឹមសារមិនត្រឹមត្រូវតាមលិខិតអនុញ្ញាត ឬគ្មានលិខិតអនុញ្ញាតរបស់ក្រសួងសុខាភិបាល ។

៤-ចុះត្រួតពិនិត្យវាយតម្លៃដោយប្រើឯកសារលក្ខណៈវិនិច្ឆ័យ (Check List) ឱ្យបានត្រឹមត្រូវក្នុងការសុំបើក សុំបិទ សុំប្ដូរទីតាំង សុំប្ដូរអ្នកទទួលខុសត្រូវ និងបន្តសុពលភាព ឱសថស្ថាន ឱសថស្ថានរង អគារលក់ឱសថបូរាណ តាមប្រកាសលេខ ០០១៤អបស/ឱអបស ចុះថ្ងៃទី ១៣ មករា ២០០៩ ស្ដីពី បែបបទ និងល័ក្ខខ័ណ្ឌក្នុងការសុំបើក សុំបិទ សុំប្ដូរទីតាំងនៃគ្រឹះស្ថានលក់ឱសថ ។ ដោយឡែកចំពោះសាខាគ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថ សាខាគ្រឹះស្ថានអាហរ័ណ នីហរ័ណគ្រឿងសម្អាង និងមជ្ឈមណ្ឌលថែរក្សាសម្ផស្សនៅតាមខេត្ត ការចុះត្រួតពិនិត្យវាយតម្លៃ ដោយប្រើឯកសារលក្ខណៈវិនិច្ឆ័យ (Check List) ត្រូវធ្វើតាមរយៈមន្ទីរសុខាភិបាលខេត្ត រួចផ្ញើមកក្រសួងសុខាភិបាល (នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង) ។

៥-ចុះត្រួតពិនិត្យតាមដាន និងមានវិធានការលុបបំបាត់កន្លែងលក់ឱសថអត់ច្បាប់

៦-ត្រូវធ្វើរបាយការណ៍សកម្មភាពការងាររបស់ភ្នាក់ងារត្រួតពិនិត្យឱសថ បរិក្ខារពេទ្យ និងគ្រឿងសម្អាង មកក្រសួងសុខាភិបាល (នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង) រៀងរាល់ត្រីមាស ។

**ប្រការ ៤.-**

**តួនាទី និងភារកិច្ចរបស់ភ្នាក់ងារត្រួតពិនិត្យចំណីអាហារ :**

**ក.វិសាលភាព :**

១-ភ្នាក់ងារត្រួតពិនិត្យអនាម័យ និងសុវត្ថិភាពចំណីអាហារថ្នាក់កណ្ដាលមានវិសាលភាពត្រួតពិនិត្យទូទាំងព្រះរាជាណាចក្រកម្ពុជា រាល់សកម្មភាពដែលទាក់ទងនឹងអនាម័យ និងសុវត្ថិភាពចំណីអាហារ ។

**ខ-ភ្នាក់ងារត្រួតពិនិត្យអនាម័យ និងសុវត្ថិភាពចំណីអាហារថ្នាក់រាជធានី ខេត្តមានភារកិច្ច :**

១-ចុះត្រួតពិនិត្យតាមដានការអនុវត្តន៍លិខិតបទដ្ឋានគតិយុត្តិ របស់ក្រសួងសុខាភិបាល ស្ដីពីអនាម័យ និងសុវត្ថិភាពចំណីអាហារទាំងអស់ក្នុងរាជធានី ខេត្ត ឱ្យបានមួយកន្លែង១ដង ក្នុង១ត្រីមាស ដោយប្រើឯកសារលក្ខណៈវិនិច្ឆ័យ (Check List) ក្នុងការវាយតម្លៃ ។

២-ចុះត្រួតពិនិត្យវាយតម្លៃទីតាំងក្នុងការស្នើសុំវិញ្ញាបនប័ត្រអនាម័យចំណីអាហារ ។ ដោយឡែក ចំពោះគ្រឹះស្ថានផលិតចំណីអាហារ នៅតាមរាជធានី ខេត្ត ការចុះត្រួតពិនិត្យវាយតម្លៃដោយប្រើឯកសារលក្ខណៈវិនិច្ឆ័យ (Check List) ត្រូវធ្វើតាមរយៈមន្ទីរសុខាភិបាលរាជធានី ខេត្ត រួចផ្ញើមកក្រសួងសុខាភិបាល (នាយកដ្ឋាន ឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង) ។

៣-ពេលភ្នាក់ងារត្រួតពិនិត្យអនាម័យ និងសុវត្ថិភាពចំណីអាហារ របស់ក្រសួងសុខាភិបាលចុះធ្វើការត្រួតពិនិត្យកន្លែងដូចមានចែងក្នុងប្រការ៤ ភ្នាក់ងារត្រួតពិនិត្យអនាម័យ និងសុវត្ថិភាពចំណីអាហាររាជធានី ខេត្ត ត្រូវសហការគ្រប់ពេល ដើម្បីអនុវត្តការងារត្រួតពិនិត្យឱ្យបានល្អប្រសើរ ។

៤-តាមដានត្រួតពិនិត្យការផ្សព្វផ្សាយពាណិជ្ជកម្ម នូវផលិតផលសម្រាប់ចិញ្ចឹមទារកកុមារ និងផលិតផលប្រហាក់ប្រហែល តាមរយៈវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្ដី ព្រឹត្តប័ត្រវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ សិក្ខាសាលា ឬតាមរូបភាពផ្សេង១ទៀត ដែលគ្មានលិខិតអនុញ្ញាតពីក្រសួងសុខាភិបាល។

៥-គ្រប់របាយការណ៍សកម្មភាពការងាររបស់ភ្នាក់ងារត្រួតពិនិត្យអនាម័យ និងសុវត្ថិភាពចំណីអាហាររាជធានី ខេត្ត ត្រូវផ្ញើមកក្រសួងសុខាភិបាល (នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង) រៀងរាល់ត្រីមាស ។

**ប្រការ ៦.-**

**តួនាទីនិងភារកិច្ចរបស់ភ្នាក់ងារត្រួតពិនិត្យសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន :**

**ក. វិសាលភាព :**

ភ្នាក់ងារត្រួតពិនិត្យសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន បែងចែកជា :

១-ភ្នាក់ងារត្រួតពិនិត្យសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជនថ្នាក់កណ្ដាលមានវិសាលភាពត្រួតពិនិត្យ ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

២-ភ្នាក់ងារត្រួតពិនិត្យសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជនថ្នាក់រាជធានី ខេត្ត មានវិសាលភាពត្រួតពិនិត្យតែក្នុងដែនសមត្ថកិច្ចប៉ុណ្ណោះ ។

២-ចុះតាមដានស្រាវជ្រាវការចរាចរណ៍ផលិតផលចំណីអាហារនៅលើទីផ្សារ ក្នុងករណីសង្ស័យ ត្រូវធ្វើសម្រង់ផលិតផលចំណីអាហារ និងរាយការណ៍ជូនថ្នាក់ដឹកនាំ ដើម្បីសម្រេច ។

៣-ចុះត្រួតពិនិត្យតាមដានការអនុវត្តន៏វិសហមជ្ឈការ និងវិមជ្ឈការរបស់ក្រសួងសុខាភិបាល នៅតាមបណ្តាមន្ទីរសុខាភិបាលរាជធានី ខេត្ត ក្នុង១ឆ្នាំ៤ដង ដោយប្រើឯកសារលក្ខណៈវិនិច្ឆ័យ (Check List) ក្នុងការវាយតម្លៃ ។

៤-សហការជាមួយក្រសួងពាក់ព័ន្ធក្នុងការត្រួតពិនិត្យអនាម័យតាមគ្រឹះស្ថានផលិត ចំណីអាហារ

៥-ចូលរួមជាមួយក្រសួងពាក់ព័ន្ធស្រាវជ្រាវទប់ស្កាត់នូវផលិតផលចំណីអាហារ ផលិតផល សម្រាប់ចិញ្ចឹមទារក និងកុមារ ឬផលិតផលប្រហាក់ប្រហែលខុសច្បាប់ ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

៦-តាមដានត្រួតពិនិត្យការផ្សព្វផ្សាយពាណិជ្ជកម្មនូវផលិតផលសម្រាប់ចិញ្ចឹមទារក និង ផលិតផលប្រហាក់ប្រហែល តាមរយៈវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី ព្រឹត្តប័ត្រវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ សិក្ខាសាលា ឬតាមរូបភាពផ្សេងៗទៀត ដើម្បីលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ឬ ផលិតផលប្រហាក់ប្រហែល ដាក់តាំងតាមទីផ្សារ ទីសាធារណៈ ឬតាមឱសថស្ថាន ឱសថស្ថានរង និងប្រព័ន្ធ ថែទាំសុខភាព ។

៧-បញ្ឈប់ការផ្សព្វផ្សាយតាមគ្រប់រូបភាពដើម្បីលក់នូវផលិតផលសំរាប់ចិញ្ចឹមទារកនិងកុមារ និងផលិតផលប្រហាក់ប្រហែល ដែលមានខ្លឹមសារផ្ទុយពីលិខិតអនុញ្ញាតរបស់ក្រសួងសុខាភិបាល ឬមានខ្លឹមសារ ផ្ទុយពីអនុក្រឹត្យលេខ ១៣៣ អនក្រ.បក ។

៨-ចុះត្រួតពិនិត្យតាមដានរាល់ពាក្យបណ្តឹងរបស់អ្នកប្រើប្រាស់ផលិតផលចំណីអាហារ និង ផលិតផលសម្រាប់ចិញ្ចឹមទារក កុមារ ឬផលិតផលប្រហាក់ប្រហែលទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

១០-ពេលចុះអនុវត្តការងារក្នុងកន្លែងប្រកបអាជីវកម្មដូចក្នុងប្រការ៤ ភ្នាក់ងារត្រួតពិនិត្យ អនាម័យ និងសុវត្ថិភាពចំណីអាហារ មានសិទ្ធិឃាត់ទុកជាបណ្តោះអាសន្ននូវផលិតផលចំណីអាហារ និង ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ ឬផលិតផលប្រហាក់ប្រហែល ក្លែងក្លាយខូចគុណភាព ហួសកំណត់កាល បរិច្ឆេទប្រើប្រាស់ និងមានប្រើសារធាតុគីមីបន្ថែម (Food Additives) ដែលក្រសួងសុខាភិបាល ឬក្រសួង ពាក់ព័ន្ធបានហាមឃាត់ និងត្រូវធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ ដើម្បីសម្រេច ។

១១-ក្នុងករណីភោជនីយដ្ឋាន ឬអាហារដ្ឋានណា ពុំគោរពតាមការណែនាំ គោលការណ៍ អនាម័យ និងសុវត្ថិភាពរបស់ក្រសួងសុខាភិបាល ឬបង្កឱ្យមានផលប៉ះពាល់សុខភាព និងអាយុជីវិតរបស់ ប្រជាពលរដ្ឋ នោះភ្នាក់ងារត្រួតពិនិត្យអនាម័យ និងសុវត្ថិភាពចំណីអាហារ ត្រូវធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ ក្រសួងសុខាភិបាល និងក្រសួងពាក់ព័ន្ធ ដើម្បីសុំសេចក្តីសម្រេច ។

**គ-នីតិវិធីក្នុងការចុះត្រួតពិនិត្យ :**

រាល់ការចុះប្រតិបត្តិការ ភ្នាក់ងារត្រួតពិនិត្យសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន ត្រូវ :

-មានលិខិតបញ្ជាបេសកកម្ម ដែលចេញដោយប្រធានស្ថាប័នសាមី ។

-មានឯកសណ្ឋានជាភ្នាក់ងារត្រួតពិនិត្យ ។

ប្រការ ៧.-

**ការបែងចែកភារកិច្ចរវាងភ្នាក់ងារត្រួតពិនិត្យសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន ថ្នាក់កណ្តាល និង ថ្នាក់រាជធានី ខេត្ត**

**ក-ភ្នាក់ងារត្រួតពិនិត្យសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជនថ្នាក់កណ្តាល មានភារកិច្ច :**

១-ចុះត្រួតពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តន៍ ច្បាប់ អនុក្រឹត្យ ប្រកាស សារាចរណែនាំ និងសេចក្តីជូនដំណឹងផ្សេងៗ របស់ក្រសួងសុខាភិបាល ស្តីពី ការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ជំនួយវេជ្ជសាស្ត្រ និងមជ្ឈមណ្ឌលកែសម្ផស្សនៅតាមមន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរព្យាបាលជម្ងឺកុមារ មន្ទីរសម្ភព-រោគស្ត្រី មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរព្យាបាលមាត់-ធ្មេញ មជ្ឈមណ្ឌលកែសម្ផស្ស មន្ទីរព្យាបាលជម្ងឺភ្នែក មន្ទីរព្យាបាលជំងឺត្រចៀក-ច្រមុះ-បំពង់ក មន្ទីរព្យាបាលជម្ងឺសើស្បែក មន្ទីរព្យាបាលជម្ងឺផ្លូវចិត្ត ការិយាល័យទំនាក់ទំនងបញ្ជូនជម្ងឺ សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជនផ្សេងៗទៀត ក្នុងករណីចាំបាច់នៅទូទាំងរាជធានី ខេត្ត ។

២-ចុះត្រួតពិនិត្យ និងវាយតម្លៃរាល់ការស្នើសុំបើក ឬបិទ សុំកែទ្រង់ទ្រាយ ឬប្តូរទីតាំង ឬប្តូរអ្នកទទួលខុសត្រូវបច្ចេកទេស មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរព្យាបាលជម្ងឺកុមារ មន្ទីរសម្ភព-រោគស្ត្រី មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរព្យាបាលមាត់-ធ្មេញ មជ្ឈមណ្ឌលកែសម្ផស្ស មន្ទីរព្យាបាលជម្ងឺភ្នែក មន្ទីរព្យាបាលជម្ងឺត្រចៀក-ច្រមុះ-បំពង់ក មន្ទីរព្យាបាលជម្ងឺសើស្បែក មន្ទីរព្យាបាលជម្ងឺផ្លូវចិត្ត ការិយាល័យទំនាក់ទំនងបញ្ជូនជម្ងឺ សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជនផ្សេងៗទៀត ក្នុងករណីចាំបាច់នៅទូទាំងរាជធានី ខេត្ត ។

៣-ចុះពង្រឹងការអនុវត្តន៍ច្បាប់ អនុក្រឹត្យ ប្រកាស សារាចរណែនាំនិងសេចក្តីជូនដំណឹងផ្សេងៗ របស់ក្រសួងសុខាភិបាល ស្តីពីការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជនផ្សេងៗទៀតក្នុងករណីចាំបាច់ ដល់អ្នកគ្រប់គ្រង និងភ្នាក់ងារត្រួតពិនិត្យសេវាឯកជន នៅទូទាំងរាជធានី ខេត្ត ។

**ខ.តួនាទី និង ភារកិច្ច :**

ភ្នាក់ងារត្រួតពិនិត្យសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន មានភារកិច្ចណែនាំ ត្រួតពិនិត្យ និងតាមដានការអនុវត្តន៍ ច្បាប់ អនុក្រឹត្យ ប្រកាស សារាចរណែនាំ និងសេចក្តីជូនដំណឹងផ្សេងៗ ស្តីពី ការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជននៅតាម :

-បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ

-បន្ទប់ថែទាំជម្ងឺ

-បន្ទប់ព្យាបាលដោយចលនា

-បន្ទប់ពិគ្រោះព្យាបាលជម្ងឺ

-បន្ទប់ពិគ្រោះព្យាបាលជម្ងឺមាត់ ធ្មេញ

-បន្ទប់ពិគ្រោះព្យាបាលជម្ងឺភ្នែក

-បន្ទប់ពិគ្រោះព្យាបាលជម្ងឺត្រចៀក ច្រមុះ បំពង់ក

-បន្ទប់ពិគ្រោះព្យាបាលជម្ងឺសើស្បែក

-បន្ទប់ពិគ្រោះព្យាបាលជម្ងឺផ្លូវចិត្ត

-មន្ទីរពេទ្យឯកជន

-មន្ទីរពហុព្យាបាល

-មន្ទីរសម្រាកព្យាបាល

-មន្ទីរព្យាបាលជម្ងឺកុមារ

-មន្ទីរសម្ភពរោគស្ត្រី

-មន្ទីរពិសោធន៍វេជ្ជសាស្ត្រ

-មន្ទីរព្យាបាលមាត់ ធ្មេញ

-មជ្ឈមណ្ឌលកែសម្ផស្ស

-មន្ទីរព្យាបាលជម្ងឺភ្នែក

-មន្ទីរព្យាបាលជម្ងឺត្រចៀក ច្រមុះ បំពង់ក

-មន្ទីរព្យាបាលជម្ងឺសើស្បែក

-មន្ទីរព្យាបាលជម្ងឺផ្លូវចិត្ត

-ការិយាល័យទំនាក់ទំនងបញ្ជូនជម្ងឺ

-សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជនផ្សេងៗទៀត ក្នុងករណីចាំបាច់ ។

២-សហការជាមួយភ្នាក់ងារត្រួតពិនិត្យសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជនថ្នាក់កណ្តាល (នាយកដ្ឋានមន្ទីរពេទ្យ) ។

៣-តាមដាន ត្រួតពិនិត្យ ការផ្សព្វផ្សាយពាណិជ្ជកម្ម សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជនតាមរយៈ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី ខិត្តប័ណ្ណ និងតាមរូបភាពផ្សេងៗ ដែលមានខ្លឹមសារមិនត្រឹមត្រូវតាមលិខិតអនុញ្ញាត ឬគ្មានលិខិតអនុញ្ញាតពីក្រសួងសុខាភិបាល ។

៤- ចុះត្រួតពិនិត្យតាមដាន និងមានវិធានការលុបបំបាត់សេវាសុខាភិបាលខុសច្បាប់ ។

៥-ធ្វើរបាយការណ៍សកម្មភាពសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជនប្រចាំឆមាស និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងសុខាភិបាល (នាយកដ្ឋានមន្ទីរពេទ្យ) ឱ្យបានទៀងទាត់ ។

**ប្រការ ៨.-**

**កិច្ចសហការរវាងភ្នាក់ងារត្រួតពិនិត្យឱសថ បរិក្ខារពេទ្យ និងគ្រឿងសម្អាង និងភ្នាក់ងារត្រួតពិនិត្យសេវាសុខាភិបាលឯកជន :**

-ក្នុងករណីមានការបើកឱសថស្ថាន ឱសថស្ថានរង ក្នុងសេវាសុខាភិបាលឯកជន ឬក្នុងករណីឱសថស្ថាន ឱសថស្ថានរង អគារលក់ឱសថបូរាណ គ្រឹះស្ថានអាហារ៍ណ នីហារ៍ណ មានបើកពិគ្រោះ ពិនិត្យព្យាបាល ថែទាំជម្ងឺ នោះភ្នាក់ងារត្រួតពិនិត្យឱសថ បរិក្ខារពេទ្យ និងគ្រឿងសម្អាង និងភ្នាក់ងារត្រួតពិនិត្យសេវាសុខាភិបាលឯកជន ត្រូវសហការគ្នាចុះត្រួតពិនិត្យក្នុងការអនុវត្តន៍ និងមានវិធានការតាមច្បាប់ ។

-សហការត្រួតពិនិត្យកន្លែងលក់ផលិតផល និងឧបករណ៍បំរើសេវាសុខាភិបាលដែលគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

**ប្រការ ៩.-**

ជនណារារាំងប្រឆាំងនឹងការអនុវត្តន៍ភារកិច្ចរបស់ភ្នាក់ងារត្រួតពិនិត្យសុខាភិបាល ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ ១០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

៤-ចុះត្រួតពិនិត្យតាមដានការអនុវត្តនីតិវិធីសហមជ្ឈការ និងវិមជ្ឈការរបស់ក្រសួងសុខាភិបាល នៅតាមបណ្តាមន្ទីរសុខាភិបាលរាជធានី ខេត្ត រៀងរាល់ត្រីមាស ដោយប្រើឯកសារលក្ខណៈវិនិច្ឆ័យ (Check List) ក្នុងការវាយតម្លៃ។

៥-ចុះត្រួតពិនិត្យសេវាខុសច្បាប់ និងរាល់ករណីអនុវត្តខុសលិខិតបទដ្ឋានគតិយុត្តិដែលកើតមានឡើងនៅតាមបន្ទប់ពិនិត្យស្ត្រីមានផ្ទៃពោះ បន្ទប់ថែទាំជម្ងឺ បន្ទប់ព្យាបាលដោយចលនា បន្ទប់ពិគ្រោះព្យាបាលជម្ងឺ បន្ទប់ពិគ្រោះព្យាបាលជម្ងឺមាត់-ធ្មេញ មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរព្យាបាលជម្ងឺកុមារ មន្ទីរសម្ភព-រោគស្ត្រី មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរព្យាបាលមាត់-ធ្មេញ មជ្ឈមណ្ឌលកែសម្ផស្ស មន្ទីរព្យាបាលជម្ងឺភ្នែក មន្ទីរព្យាបាលជម្ងឺត្រចៀក-ច្រមុះ-បំពង់ក មន្ទីរព្យាបាលជម្ងឺសើស្បែក មន្ទីរព្យាបាលជម្ងឺផ្លូវចិត្ត ការិយាល័យតំណាងមន្ទីរពេទ្យ និងការិយាល័យទំនាក់ទំនងបញ្ជូនជម្ងឺនៅទូទាំងរាជធានី ខេត្ត ។

៦-តាមដានត្រួតពិនិត្យការផ្សព្វផ្សាយពាណិជ្ជកម្មសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រឯកជន តាមរយៈវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី ខិតប័ណ្ណ និងតាមរូបភាពផ្សេងៗ ដែលមានខ្លឹមសារមិនត្រឹមត្រូវតាមលិខិតអនុញ្ញាត ឬគ្មានលិខិតអនុញ្ញាត ពីក្រសួងសុខាភិបាល ។

៧-ភ្នាក់ងារត្រួតពិនិត្យមានសិទ្ធិផ្អាកសកម្មភាពបណ្តោះអាសន្ន សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន ក្នុងករណីមានបទល្មើសដែលប៉ះពាល់ដល់សុខភាព ឬអាយុជីវិតប្រជាជន កើតមានឡើង ។

៨-ធ្វើរបាយការណ៍ស្ថិតិសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ជំនួយវេជ្ជសាស្ត្រឯកជន ដែលបានមកពីគ្រប់រាជធានី ខេត្ត រៀងរាល់ឆមាស និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំក្រសួងសុខាភិបាល ។

**ខ-ភ្នាក់ងារត្រួតពិនិត្យសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន ថ្នាក់រាជធានី ខេត្ត មានភារកិច្ច :**

១-ចុះត្រួតពិនិត្យ និងវាយតម្លៃរាល់ការស្នើសុំបើក ឬប្តូរទីតាំង ឬប្តូរអ្នកទទួលខុសត្រូវបច្ចេកទេសមន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរព្យាបាលជម្ងឺកុមារ មន្ទីរសម្ភព-រោគស្ត្រី មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរព្យាបាលមាត់-ធ្មេញ និងជំនួយមន្ទីរព្យាបាលជម្ងឺភ្នែក មន្ទីរព្យាបាលជម្ងឺត្រចៀក-ច្រមុះ-បំពង់ក មន្ទីរព្យាបាលជម្ងឺសើស្បែក មន្ទីរព្យាបាលជម្ងឺផ្លូវចិត្ត ហើយធ្វើរបាយការណ៍ចុះត្រួតពិនិត្យ បញ្ជូនមកនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល។

**<u>ប្រការ ១១.</u>-**

ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង នាយកដ្ឋានមន្ទីរពេទ្យ មន្ទីរសុខាភិបាលរាជធានី ខេត្ត ភ្នាក់ងារត្រួតពិនិត្យឱសថ បរិក្ខារពេទ្យ និងគ្រឿងសម្អាង ភ្នាក់ងារត្រួតពិនិត្យអនាម័យ និងសុវត្ថិភាពចំណីអាហារ និងភ្នាក់ងារត្រួតពិនិត្យសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន មានភារកិច្ចអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀង១ខ្លួន ។

**<u>ប្រការ ១២.</u>-**

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**<u>កន្លែងទទួល</u> :**

-ដូចប្រការ ១១

-ឯកសារ-កាលប្បវត្តិ

**ម៉ម_ប៊ុនហេង**